**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១១)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ២ ២៩០នាក់ នៃរោងចក្រ សហគ្រាស ទាំង២៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ ដើម្បីចៀសវាងការលំបាកក្នុងការបង្វិលថវិកាសងរាជរដ្ឋាភិបាលវិញ ក្នុងករណីរោងចក្រ សហគ្រាសសុំចូលធ្វើការមុនកាលកំណត់នៃរយៈពេលព្យួរកិច្ចសន្យាការងារ នោះប្រាក់ឧបត្ថម្ភនឹងត្រូវចែកចេញជា ២ដង សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងារចាប់ពី ២១ថ្ងៃ ដល់ ១ខែ, និងត្រូវបែងចែកជា ៤ដង សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ដោយក្នុង ១ដង ស្មើនឹងថវិកាចំនួន ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក)។

ក្រសួងសូមរំឮកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង២៤ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ ពុធ ៣ រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០២០*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០

បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
ចំនួន ២៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 15 |
| 1 | ក្រុមហ៊ុនខូក វើលដ៍ ថយស៍ ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុនវ៉ាយ វី ភី គ្រេឌីង | ភ្នំពេញ |
| 3 | ក្រុមហ៊ុនយែនធើវេន អឹកែវីល (ខេមបូឌា) | ភ្នំពេញ |
| 4 | ក្រុមហ៊ុនម៉ានីងគ្លរី ហ្គាមេន អេនធើប្រាយ | ភ្នំពេញ |
| 5 | ក្រុមហ៊ុនណាហ្គាភីស ឧបភើរេសិន លីមីធីត_1 | កណ្តាល |
| 6 | ក្រុមហ៊ុនថៃ យ៉ា ហ្គាមេន អ៊ិនដាសស្ទ្រី | កណ្តាល |
| 7 | ក្រុមហ៊ុនរីជេន ហ្វ៊ូតវែរ (ខេមបូឌា) ខូ អិលធីឌី | កណ្តាល |
| 8 | ក្រុមហ៊ុនតុងឆាយ | កណ្តាល |
| 9 | ក្រុមហ៊ុនតើហ្វម វែល ហូលឌីង (ខេមបូឌា) លីមីធីត | កណ្តាល |
| 10 | ក្រុមហ៊ុនបូវយើ ហ្គាមេន ព្រីនធីង(ខេមបូឌា)ខមភេនី លីមីធីត | កណ្តាល |
| 11 | ក្រុមហ៊ុនចិចសាន់(ខេមបូឌា)នីតធីង វ៉ស៊ីង ដាយអ៊ីង អេន ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុនម៉ូណូភា (ខេមបូឌា) ខូ អិល ធីឌី | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុនស្ត្រង ហែលធ៍ អ៊ិនធើណេសិនណល លីមីធីត | តាកែវ |
| 14 | ក្រុមហ៊ុនណាញ ស្វាយ ហ្គាម៉ិន ឯ.ក | តាកែវ |
| 15 | ក្រុមហ៊ុនខតថិនខនសិប អ៊ិនដាសស្ទ្រី ឯ.ក | តាកែវ |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ខ. វិស័យទេសចរណ៍ | | 9 |
| 16 | ក្រុមហ៊ុនផ្លូតីថរ៉ា រីសត & ស្ប៉ា (ខេមបូឌា) | ភ្នំពេញ |
| 17 | ក្រុមហ៊ុន៥ អូសិន ខូអិលធីឌី | ភ្នំពេញ |
| 18 | ក្រុមហ៊ុនអេប៊ិច ខេមបូឌា ត្រាវ៉ែល សែរវីស | សៀមរាប |
| 19 | ក្រុមហ៊ុនតូបេ យៃតែននីស វិស្ហូវែន | សៀមរាប |
| 20 | ក្រុមហ៊ុនអេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 21 | ក្រុមហ៊ុនប៉ូរ ឃ្វីហ្សីន | សៀមរាប |
| 22 | សណ្ឋាគារ វីណាហ្គូហ្វ អង្គរ | សៀមរាប |
| 23 | ក្រុមហ៊ុនមុទិតា រីសត & ស្ប៉ា | សៀមរាប |
| 24 | ក្រុមហ៊ុនឡាយ ហ្គូលយ៉ាណា អង្គរ ហូថេល ឯ.ក | សៀមរាប |